FEED THE FUTURE
The U.S. Government's Global Hunger & Food Security Initiative


**អ្នកនិពន្ធ៖ ជា ប៊ុនណា[1], កង ក្រឹស្នា[1], Jessie Vipham[2], Lisa Tokach[3], Mike Tokach[2]**

[1] មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ភ្នំពេញ កម្ពុជា

[2] Department of Animal Sciences and Industry, Kansas State University, Manhattan, Kansas, USA

[3] Abilene Animal Hospital, Abilene, Kansas, USA




# ភាគ២
# Part 2

# ជំងឺជ្រូក និងវិធានការការពារ
# Pig Disease and Prevention

ឈ្មោះគម្រោង៖

«**លើកស្ទួយចំណី និងសុខភាពជ្រូក៖** ចលករចម្បងនៃផលចំណេញ និងនិរន្តភាពសម្រាប់កសិករខ្នាតតូចនៅកម្ពុជា»

ប្រភពថវិកា៖ Livestock Systems Innovation Lab


ព័ត៌មានបន្ថែមសូមទាក់ទង៖ លោក ជា ប៊ុនណា

លេខទូរស័ព្ទ៖ (៨៥៥)៦៩ ៩២១ ៦៦២

សារអេឡិចត្រូនិច៖ bunna_chea@rua.edu.kh


## កម្មវិធីផ្សព្វផ្សាយកសិកម្មស៊ីសេន

## CE SAIN Agricultural Extension Program

កម្មវិធីនេះបំពេញមុខវេទិកាមួយដែលជួយសម្របសម្រួលដល់កសិករ ស្ថាប័នអប់រំ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការទទួលព័ត៌មាន ចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ទាក់ទងនឹងបច្ចេកទេសកសិកម្ម ដើម្បីធានាដល់ការផ្សព្វផ្សាយការអនុវត្តការគ្រប់គ្រងកសិកម្មល្អៗ។ កម្មវិធីនេះជួយធ្វើឲ្យប្រសើរឡើងនូវ ចំណេះដឹង និងការអនុវត្តបច្ចេកទេសកសិកម្មដោយផ្អែកលើនវានុវត្តន៍ និង ការស្រាវជ្រាវវិទ្យាសាស្ត្រជាមូលដ្ឋាន។

### កត្តាដែលអាចចម្លងជំងឺដល់ជ្រូកអ្នក និង ដំណោះស្រាយ

**ក. ប្រភពជ្រូកផ្សេងៗគ្នា**

- ទទួលបានពីអង្គការនានា
- ទិញពីកសិដ្ឋាន
- អ្នកដឹកដើរលក់តាមម៉ូតូ /កង់

ដំណោះស្រាយ៖
- ត្រូវដឹងពីសុខភាពជ្រូកដែលអ្នកមានបំណងទិញមកចិញ្ចឹម
- កុំដាក់ជ្រូកចិញ្ចឹមលាយឡំគ្នា ដែលទិញមកពីប្រភពផ្សេងៗគ្នា
- ព្យាយាមកុំឲ្យអ្នកទិញជ្រូក ចេញ ឬចូលក្នុងទ្រុងជ្រូករបស់អ្នក

**ខ. ការផ្តល់កាកសំណល់ភោជនីយដ្ឋាន/ផ្ទះបាយ**

ដំណោះស្រាយ៖
- កុំផ្តល់កំទេចសាច់ជ្រូកដល់ជ្រូករបស់អ្នក
- ត្រូវចម្អិនកាកសំណល់ទាំងនោះ និងទុកដាក់ឲ្យបានត្រឹមត្រូវ មុនផ្តល់ឲ្យជ្រូកស៊ី

(ហានិភ័យដោយជំងឺ បង្កដោយពពួកបាក់តេរី និងវីរុស ដូចជាជំងឺអុតក្តាម ឆ្លូតជ្រូក និងជំងឺប៉េស្តជ្រូកអាហ្វ្រិច)



## គ

ការចិញ្ចឹមសត្វផ្សេងៗលាយឡំជាមួយជ្រូកអាចបង្ករជំងឺផ្សេងៗ៖

ជ្រូកព្រៃ៖ អាចចម្លងជំងឺដល់ជ្រូកអ្នកប្រសិនបើមកជិតជ្រូកអ្នក

⚠ ធ្វើរបងដើម្បីបង្ខាំងកុំឲ្យមកក្បែរជ្រូកអ្នក

ជ្រូកងាប់៖ អាចចម្លងជំងឺដល់ជ្រូកអ្នកក្នុងទ្រុង

⚠ យកចេញពីទ្រុងភ្លាមៗ រួចកប់/ដុតចោល

សត្វផ្សេងទៀត៖ ចម្លងមេរោគទៅលើជ្រូក និងពាំយកសាកសពសត្វងាប់មកចម្លងជ្រូកអ្នក

⚠ ធ្វើរបងការពារកុំឲ្យវាចូល/ពាំសាកសពសត្វចូលទ្រុងជ្រូក

សត្វកកេរ៖ ចម្លងមេរោគទៅលើចំណី និងជំងឺផ្សេងៗ

⚠ ដាក់អន្ទាក់ និងទុកដាក់សម្ភារប្រើប្រាស់ក្នុងទ្រុងឲ្យត្រឹមត្រូវ និងស្អាត

បក្សីផ្សេងទៀត៖
សត្វល្អិត៖
.ចម្លងមេរោគលើចំណី
.ជំងឺផ្តាសាយបក្សី
.ចម្លងជំងឺតាមឈាម
.ដង្កៃផ្ទុកជំងឺប៉េស្តជ្រូកអាហ្វ្រិច

⚠ ដាក់មុង/សំណាញ់ជុំវិញទ្រុងជ្រូកកុំឲ្យបក្សីផ្សេងៗ និងសត្វល្អិតចូលក្បែរជ្រូកអ្នក

## ឃ

ការប្រើសម្ភារផ្សេងៗលើជ្រូករួមគ្នាដូចជា៖

ម្ជុល៖
- ✓ ត្រូវតែស្អាត/សម្អាតម្ជុលដោយសាប៊ូ/ថ្នាំលាងសម្អាតមុនយកចូលទ្រុងជ្រូក /ប្រើចាក់ជ្រូក
- ✓ ចាំបាច់ប្តូរម្ជុលរវាងពីជ្រូកមួយទ្រុងទៅជ្រូកមួយទ្រុង និងប្តូរម្ជុលរវាងកូនជ្រូកមួយសំបុកជាការល្អ



ជញ្ជីង ធុងដាក់ចំណី ដុជជ្រូក ប្រដាប់កាត់ធ្មេញ ឈើលើកជ្រូក និងសម្ភារប្រើប្រាស់ផ្សេងៗ៖



- ✓ លាងសម្អាត/ប្រើថ្នាំសម្លាប់មេរោគនៅពេលដែលយកពីទ្រុងជ្រូកមួយទៅទ្រុងជ្រូកមួយទៀតរបស់អ្នក ឬពីទ្រុងជ្រូកអ្នកទៅទ្រុងជ្រូកអ្នកជិតខាង

## ង

អ្នកដទៃដែលមកមើលជ្រូកអ្នកដូចជា៖ អ្នកជិតខាង ពេទ្យសត្វ អ្នកមកទិញជ្រូក អ្នកដាក់បាជ្រូក និងអ្នកលក់បន្លែសាច់តាមផ្ទះ។ អ្នកត្រូវ៖



ប្រាប់អ្នកជិតខាងដែលមានជ្រូក ឬបានទៅមើលជ្រូកកន្លែងផ្សេងៗ៖



អ្នកអាចពន្យល់ប្រាប់អ្នកជិតខាងពីហេតុផលដែលអ្នករឹតបណ្តឹងការចូលមើលជ្រូកអ្នកក្នុងន័យការពារសុខភាពជ្រូកអ្នក។

ប្រាប់ពេទ្យសត្វភូមិ ឬបសុពេទ្យ

ម្ចាស់ជ្រូកត្រូវប្រាប់ពីប្រព័ន្ធជីវសុត្ថិភាព ឬពេទ្យត្រូវសួរម្ចាស់សត្វពីជីវសុវត្ថិភាពមុនចូលព្យាបាលសត្វបើមាន។

- ដាក់សញ្ញាហាមឃាត់នៅក្បែរទ្រុងជ្រូកអ្នក
- កុំឲ្យយកយាន្តជំនិះទៅជិតទ្រុងជ្រូកអ្នក
- លាងសម្អាតដៃមុនចូលមើលជ្រូកអ្នក
- ពាក់ថង់ប្លាស្ទិចលើជើង ឬយើងផ្តល់ស្បែកជើងឲ្យពាក់ចូលទ្រុងជ្រូក

### អ្នកមកទិញជ្រូក

- លាងសម្អាតដុជ រ៉ឺម៉ក់ ម៉ូតូឲ្យបានស្អាត និងគួរតែមិនមានដាក់ជ្រូកមកតាមមុនចូលទ្រុងជ្រូកអ្នក។
- ប្រសិនបើមានជ្រូកក្នុងដុជមកជាមួយ កុំឲ្យជ្រូកទាំងនោះប៉ះជ្រូកអ្នក។
- អ្នកអាចចាប់ជ្រូកអ្នកទៅឲ្យអ្នកទិញ និងលាងសម្អាតសម្ភារទាំងនោះឲ្យបានស្អាត។
- ការប្រើសម្ភារចាប់ជ្រូកគឺចាំបាច់ណាស់ ប៉ុន្តែអ្នកគួរលាងសម្អាត និងសម្ងួតវាមុនពេលប្រើរួមគ្នា។







### អ្នកដាក់បាជ្រូក

- លាងសម្អាតបាជ្រូក រ៉ឺម៉ក់ ម៉ូតូឲ្យបានស្អាត ព្រមទាំងម្ចាស់បាជ្រូកផងដែរមុនចូលទ្រុងជ្រូកអ្នក។
- ឲ្យអ្នកបង្កាត់សិប្បនិម្មិតជ្រូកផ្តល់នូវទឹកស្លេមដែលល្អ និងប្រាកដថាគ្មានប្រឡាក់ប្រឡូកមេរោគដោយលាងសម្អាត និងទុកដាក់ឧបករណ៍បង្កាត់ឲ្យបានត្រឹមត្រូវ។

អ្នកអាចប្រាប់ថាអ្នកមានប្រព័ន្ធជីវសុត្ថិភាពមុនចូលទ្រុងជ្រូក។ ចំណាំ៖ អ្នកទិញជ្រូក អ្នកដាក់បាជ្រូក អ្នកលក់បន្លែសាច់ គួរអនុវត្តជីវសុវត្ថិភាពតាមការណែនាំរបស់កសិករ។



### អ្នកលក់បន្លែសាច់តាមផ្ទះ



- មុននឹងទិញសាច់ អ្នកត្រូវស្គាល់ឲ្យច្បាស់ថា សាច់ដែលគេលក់នោះជាសាច់សត្វមិនមានជំងឺ
- មិនត្រូវអនុញ្ញាតិឲ្យអ្នកលក់បន្លែ និងសាច់តាមផ្ទះចូលក្នុងបរិវេណផ្ទះ ឬទៅក្បែរទ្រុងជ្រូកអ្នកទេ (គួរនៅក្រៅរបង)។
- ហាមមិនឲ្យអ្នកលក់ចូលបរិវេណទ្រុងជ្រូក ឬប៉ះពាល់ជ្រូកអ្នក។